ព្រះរាជាណាចក្រកម្ពុជា

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# បទបង្ហាញ

# ស្តីពី

# ច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦

វេទិកាសាធារណៈស្តីពីការគ្រប់គ្រងថវិកាឆ្នាំ ២០១៦

ថ្ងៃទី១៨ ខែកម្ភៈ ឆ្នាំ២០១៦

# មាតិកា


១. ក្របខណ្ឌថវិកាឆ្នាំ ២០១៦

១.១ ស្ថានភាពចំណូល

១.២ ស្ថានភាពចំណាយ

១.៣ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

២. បញ្ហាប្រឈម និង វិធានការក្នុងការអនុវត្តថវិកាឆ្នាំ ២០១៦

២.១ បញ្ហាប្រឈមក្នុងការអនុវត្តថវិកាឆ្នាំ ២០១៦

២.២ វិធានការក្នុងការអនុវត្តថវិកាឆ្នាំ ២០១៦

៣.សន្និដ្ឋាន

# ផ្ទៃការឆ្នាំ២០១៦ ៖

## “ឆ្ពោះទៅរកការសម្រេចគោលដៅសំខាន់ៗបន្ថែមទៀត នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល”

# ១. ក្របខណ្ឌថវិកាឆ្នាំ ២០១៦

# មូលដ្ឋាននៃការរៀបចំក្របខណ្ឌថវិកាឆ្នាំ ២០១៦

1. **លទ្ធផលឆ្នាំ ២០១៤ និង ឆ្នាំ ២០១៥**
   - ការប្រមូលចំណូលមានការកើនឡើង ជាពិសេសចំណូលគយ និងពន្ធដារ
   - ការបង្កើនប្រសិទ្ធភាពនៃចំណាយក្នុងកម្រិតវិភាជ និងកម្រិតអនុវត្ត
   - ការដំឡើងបៀវត្ស និង ការបើកទាន់ពេលវេលា ក្នុងសប្តាហ៍ទី ៤
   - ការកែទម្រង់ប្រព័ន្ធបៀវត្ស និង ក្របខណ្ឌ ដើម្បីលើកទឹកចិត្តមន្ត្រីរាជការ
   - ការដំឡើងរបបប្រាក់បេសកកម្ម និង ការផ្តល់រង្វាន់លើកទឹកចិត្ត
   - ការបង្កើនចំណាយសម្រាប់ការកែទម្រង់នានា និង
   - ការវិនិយោគលើការពង្រឹងការតភ្ជាប់ ភាពប្រកួតប្រជែង ផលិតភាពសេដ្ឋកិច្ច និង ការទ្រទ្រង់កំណើន
2. **ក្របខណ្ឌកំណើនសេដ្ឋកិច្ច ៧% ព្រមជាមួយនឹង សេណារីយ៉ូចំណូលសុទិដ្ឋិនិយម**

# អតិរេកចរន្តមានការកើនឡើង និងឱនភាពសរុបមានការថយចុះជាលំដាប់

| សូចនាករថវិកា | ២០១៤ | | ២០១៥ | | ២០១៦ |
|---|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | អនុវត្ត (*) | ច្បាប់ |
| ចំណូលក្នុងប្រទេស (% ផ.ស.ស) | 15.53% | 17.05% | 15.76% | 16.77% | 17.53% |
| *- ចំណូលចរន្ត (% ផ.ស.ស)* | *15.18%* | *16.78%* | *15.59%* | *16.61%* | *17.37%* |
| ចំណាយថវិការដ្ឋសរុប (% ផ.ស.ស) | 20.91% | 21.55% | 20.95% | 19.13% | 22.32% |
| *- ចំណាយចរន្ត (% ផ.ស.ស)* | *12.87%* | *12.72%* | *13.09%* | *11.78%* | *14.43%* |
| អតិរេកចរន្ត (% ផ.ស.ស) | 2.31% | 4.06% | 2.50% | 4.82% | 2.93% |
| ឱនភាពសរុប (% ផ.ស.ស) | -5.39% | -4.50% | -5.19% | -2.36% | -4.79% |

**សម្គាល់÷ (*) តួលេខប៉ាន់ស្មានអនុវត្តឆ្នាំ ២០១៥**

# បង្កើនចំណូលឱ្យអស់សក្តានុពល ឆ្លើយតបមហិច្ឆតាចំណាយ ព្រមជាមួយនឹងការបង្កើនអតិរេកចរន្ត

ក្របខណ្ឌថវិការដ្ឋជា % ផសស (២០១២-២០១៦)



# ១.១ ស្ថានភាពចំណូលថវិការដ្ឋ

# ចំណូលក្នុងប្រទេសបន្តកើនឡើងខ្ពស់នៅឆ្នាំ ២០១៦



# ចំណូលចរន្តថ្នាក់ជាតិ ជាពិសេស ចំណូលសារពើពន្ធរីកចំរើនបន្ត កើនឡើងប្រសើរជាងយុទ្ធសាស្ត្រគៀរគរចំណូល

| ចំណូល | ឯកតាលានរៀល | | | កំណើនប្រចាំឆ្នាំ | | | % ផសស | | |
|---|---|---|---|---|---|---|---|---|---|
| | ២០១៤ អនុ | ២០១៥ អនុ (*) | ២០១៦ ច្បាប់ | ២០១៤ អនុ | ២០១៥ អនុ (*) | ២០១៦ ច្បាប់ | ២០១៤ អនុ | ២០១៥ អនុ (*) | ២០១៦ ច្បាប់ |
| **ចំណូលចរន្តថវិកាថ្នាក់ជាតិ** | **10,829,697** | **11,756,542** | **13,407,263** | **24.40%** | **8.56%** | **14.04%** | **15.99%** | **15.69%** | **16.36%** |
| + ចំណូលសារពើពន្ធ | 9,336,508 | 10,502,266 | 11,555,055 | 28.09% | 12.49% | 10.02% | 13.78% | 14.02% | 14.10% |
| - គយ និងរដ្ឋាករ | 5,424,235 | 5,802,486 | 6,648,000 | 37.13% | 6.97% | 14.57% | 8.01% | 7.74% | 8.11% |
| - ពន្ធដារ | 3,672,566 | 4,421,853 | 4,907,055 | 18.40% | 20.4% | 10.97% | 5.42% | 5.90% | 5.99% |
| + ចំណូលមិនមែនសារពើពន្ធ | 1,493,189 | 1,254,276 | 1,852,208 | 5.40% | -16% | 47.67% | 2.20% | 1.67% | 2.26% |

**សម្គាល់÷ (*) តួលេខប៉ាន់ស្មានអនុវត្តឆ្នាំ ២០១៥**

# ចំណូលចរន្តប្រមាណ៥០% ត្រូវបានប្រមូលដោយ អគ្គ.គយ និងរដ្ឋាករ និង ជាង ១/៣ ប្រមូលដោយអគ្គ.ពន្ធដារ



# ពន្ធផ្ទាល់នៅមានសក្តានុពលសម្រាប់ពង្រីក

ចំណែកជា%នៃចំណូលសារពើពន្ធឆ្នាំ ២០១៦



# ពន្ធក្នុងប្រទេសជាប្រភពចំណូលសារពើពន្ធដ៏សំខាន់

ចំណែកជា % នៃចំណូលសារពើពន្ធឆ្នាំ ២០១៦



# ចំណូលមូលធនក្រៅប្រទេស ផ្នែកហិរញ្ញប្បទានឥតសំណង មាននិន្នាការធ្លាក់ចុះ ចំណាយវិនិយោគបំពេញបន្ថែមដោយថវិកាជាតិ

| ចំណូល | ឯកតាលានរៀល | | | កំណើនប្រចាំឆ្នាំ | | | %ផសស | | |
|---|---|---|---|---|---|---|---|---|---|
| | ២០១៤ អនុ | ២០១៥ អនុ (*) | ២០១៦ ច្បាប់ | ២០១៤ អនុ | ២០១៥ អនុ (*) | ២០១៦ ច្បាប់ | ២០១៤ អនុ | ២០១៥ អនុ (*) | ២០១៦ ច្បាប់ |
| **ចំណូលមូលធន** | **4,441,244** | **3,952,147** | **4,205,214** | **-4.59%** | **-11.01%** | **6.40%** | **6.56%** | **5.27%** | **5.13%** |
| ក្នុងប្រទេស | 183,996 | 123,371 | 130,864 | 169.91% | -32.95% | 6.07% | 0.27% | 0.16% | 0.16% |
| ក្រៅប្រទេស | 4,257,248 | 3,828,776 | 4,074,350 | -7.18% | -10.06% | 6.41% | 6.28% | 5.11% | 4.97% |
| + មូលនិធិទ្រទ្រង់ថវិកា | 16,768 | 141,776 | 203,000 | -94.03% | 745.51% | 43.18% | 0.02% | 0.19% | 0.25% |
| + មូលធនដោយហិរញ្ញប្បទានក្រៅប្រទេស | 4,240,480 | 3,687,000 | 3,871,350 | -1.52% | -13.05% | 5.00% | 6.26% | 4.92% | 4.72% |
| - អំណោយផ្សេងៗ | 1,620,695 | 537,000 | 541,989 | -32.50% | -66.87% | 0.93% | 2.39% | 0.72% | 0.66% |
| - ការខ្ចី | 2,619,784 | 3,150,000 | 3,329,361 | 37.51% | 20.24% | 5.69% | 3.87% | 4.20% | 4.06% |

សម្គាល់÷ (*) តួលេខប៉ាន់ស្មានអនុវត្តឆ្នាំ ២០១៥

# ១.២ ស្ថានភាពចំណាយថវិការដ្ឋ

# ១.២.១ ស្ថានភាពរួម និងតាមវិស័យ

# ចំណាយចរន្តថវិការដ្ឋ កើនឡើងខ្លាំងនៅឆ្នាំ ២០១៦



# ចំណាយបន្ទុកបុគ្គលិកបន្តកើនឡើង បង្កើនជាសម្ពាធនៅលើ ចំណាយមិនមែនបុគ្គលិក និង វិនិយោគ

| ចំណាយ | ឯកតាលានរៀល | | | កំណើនប្រចាំឆ្នាំ | | | %ផសស | | |
|---|---|---|---|---|---|---|---|---|---|
| | ២០១៤ អនុ | ២០១៥ អនុ (*) | ២០១៦ ច្បាប់ | ២០១៤ អនុ | ២០១៥ អនុ (*) | ២០១៦ ច្បាប់ | ២០១៤ អនុ | ២០១៥ អនុ (*) | ២០១៦ ច្បាប់ |
| **ចំណាយថវិការដ្ឋសរុប** | **14,598,261** | **14,337,993** | **18,283,719** | **8.33%** | **-1.78%** | **27.52%** | **21.55%** | **19.13%** | **22.32%** |
| -ចំណាយចរន្តថវិការដ្ឋ | 8,616,609 | 8,830,012 | 11,825,326 | 14.29% | 2.48% | 33.92% | 12.72% | 11.78% | 14.43% |
| បន្ទុកបុគ្គលិក | 3,945,030 | 4,504,351 | 5,922,002 | 26.12% | 14.18% | 31.47% | 5.82% | 6.01% | 7.23% |
| មិនមែនបន្ទុកបុគ្គលិក | 4,671,579 | 4,325,661 | 5,903,324 | 5.91% | -7.40% | 36.47% | 6.90% | 5.77% | 7.20% |
| -ចំណាយមូលធនថវិការដ្ឋ | 5,981,652 | 5,507981 | 6,458,393 | 0.75% | -7.92% | 17.26% | 8.83% | 7.35% | 7.88% |
| វិនិយោគសាធារណៈ ហិរញ្ញប្បទានក្នុងប្រទេស | 1,429,393 | 1,490,913 | 2,077,905 | 2.94% | 4.30% | 39.37% | 2.11% | 1.99% | 2.54% |
| មូលនិធិទ្រទ្រង់ថវិកា | 87,371 | 177,988 | 250,000 | -64.97% | 103.71% | 40.46% | 0.13% | 0.24% | 0.31% |
| វិនិយោគសាធារណៈ ហិរញ្ញប្បទានក្រៅប្រទេស | 4,240,480 | 3,687,000 | 3,871,350 | -1.52% | -13.05 | 5.00% | 6.26% | 4.92% | 4.72% |

សម្គាល់÷ (*) តួលេខប៉ាន់ស្មានអនុវត្តឆ្នាំ ២០១៥

# ចំណាយបន្ទុកបុគ្គលិកថ្នាក់ជាតិ ចាប់ផ្តើមឡើងលើស ៥០% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ

| គម្រោងចំណាយ | ២០១៥អនុ (*) (លានរៀល) | ច្បាប់ ២០១៦ (លានរៀល) | កំណើន | សមាមាត្រ | %ផសស |
|---|---|---|---|---|---|
| ចំណាយចរន្តថវិការដ្ឋ | **8.830.012** | 11,825,326 | 33.92% | 100.00% | 14.43% |
| បន្ទុកបុគ្គលិក | 4,504,351 | 5,922,002 | 31.47% | 50.08% | 7.23% |
| មិនមែនបន្ទុកបុគ្គលិក | 4,325,661 | 5,903,324 | 36.47% | 49.92% | 7.20% |
| **-ថវិកាថ្នាក់ជាតិ** | **8,298,573** | **11,156,989** | **34.44%** | **94.35%** | **13.62%** |
| បន្ទុកបុគ្គលិក | 4,303,161 | 5,636,339 | 30.98% | 50.52% | 6.88% |
| មិនមែនបន្ទុកបុគ្គលិក | 3,995,412 | 5,520,650 | 38.17% | 49.48% | 6.74% |
| **-ថវិកាថ្នាក់ក្រោមជាតិ** | **974,335** | **1,181,620** | **21.27%** | **9.94%** | **1.44%** |
| បន្ទុកបុគ្គលិក | 201,189 | 285,663 | 41.99% | 24.18% | 0.35% |
| មិនមែនបន្ទុកបុគ្គលិក | 773,146 | 895,957 | 15.88% | 75.82% | 1.09% |

សម្គាល់÷ (*) តួលេខប៉ាន់ស្មានអនុវត្តឆ្នាំ ២០១៥

# ចំណាយបន្ទុកបុគ្គលិកថ្នាក់ជាតិ ចាប់ផ្តើមធំជាង ចំណាយមិនមែនបន្ទុកបុគ្គលិក



# គោលនយោបាយបៀវត្សថ្នាក់ជាតិ ឆ្នាំ ២០១៦

- គ្រោង**តម្លើងបៀវត្សសរុបអប្បរមា** ÷
  - **មន្ត្រីរាជការស៊ីវិល** ÷ ពីប្រមាណ <u>៥៥២ ៨០០ រៀល</u> ឆ្នាំ២០១៥ ដល់ប្រមាណ **<u>៦០០ ៥០០ រៀល</u>** នៅខែមករា ឆ្នាំ២០១៦, ចាប់ពីខែមេសា ឆ្នាំ២០១៦ ឡើងដល់ប្រមាណ **<u>៧០០ ៥០០ រៀល</u>**
  - **គ្រូបង្រៀន** ÷ ពីប្រមាណ <u>៦៤៦ ៤៨០ រៀល</u> ឆ្នាំ២០១៥ ដល់ប្រមាណ **<u>៧០០ ៥០០ រៀល</u>** នៅខែមករា ឆ្នាំ២០១៦, ចាប់ពីខែមេសា ឆ្នាំ២០១៦ ឡើងដល់ប្រមាណ **<u>៨០០ ៥០០ រៀល</u>**
  - **គ្រូពេទ្យ**÷ ពីប្រមាណ <u>៦៤៦ ៧២០ រៀល</u> ឆ្នាំ២០១៥ ដល់ប្រមាណ **<u>៧០០ ៥០០ រៀល</u>** នៅខែមករា ឆ្នាំ២០១៦ ,ចាប់ពីខែមេសា ឆ្នាំ២០១៦ ឡើងដល់ប្រមាណ **<u>៨០០ ៥០០ រៀល</u>**
  - **នគរបាលជាតិ (ពលបាលត្រី)**÷ ពីប្រមាណ <u>៦៤០ ០០០ រៀល</u>(ដោយគិតបញ្ចូលរបបអង្គរ) នៅឆ្នាំ ២០១៥ ទៅប្រមាណ **<u>៦៧៥ ៩៧៧ រៀល</u>**(ដោយគិតបញ្ចូលរបបអង្គរ) នៅខែមករា ឆ្នាំ២០១៦, ចាប់ពី ខែមេសា ឆ្នាំ២០១៦ ឡើងដល់ប្រមាណ **<u>៧៨៤ ៧៣០ រៀល</u>**(គិតបញ្ចូលរបបអង្គរ)
  - **យោធិន (ពលទោ)** ÷ ពីប្រមាណ <u>៥៣៣ ០០០ រៀល</u> ដល់ប្រមាណ **<u>៥៦៦ ៥០០ រៀល</u>**(មិនគិតបញ្ចូលរបបអង្គរ) នៅខែមករា ឆ្នាំ២០១៦, ចាប់ពីខែមេសាឆ្នាំ២០១៦ ឡើងដល់ប្រមាណ **<u>៦៧៥ ៥០០ រៀល</u>**(មិនគិតបញ្ចូលរបបអង្គរ) ហើយបើគិតបញ្ចូលរបបអង្គរត្រូវជាប្រមាណ **<u>៧៣៣ ៧៣០ រៀល</u>**
  - *ប្រាក់ឧបត្ថម្ភមន្ត្រីជាប់កិច្ចសន្យា នឹងដំឡើងពី ១៦ម៉ឺនរៀល ទៅ ៤០ម៉ឺនរៀល ចាប់ពីខែមករា ២០១៦*

# ចំណាយចរន្តវិស័យសង្គមកិច្ចឆ្នាំ ២០១៦ នៅតែត្រូវបានចាត់ទុកជាវិស័យអាទិភាពទីមួយ

| គម្រោងចំណាយ | ២០១៥អនុ(*) | ច្បាប់ ២០១៦ | កំណើន | %នៃចំណាយចរន្តថវិកាជាតិ | %នៃ ផសស |
|---|---|---|---|---|---|
| វិស័យរដ្ឋបាលទូទៅ | 1,296,907 | 1,597,180 | 23.15% | 14.32% | 1.95% |
| វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 2,225,933 | 2,772,857 | 24.57% | 24.85% | 3.38% |
| វិស័យសង្គមកិច្ច | 2,989,123 | 4,291,441 | 43.57% | 38.46% | 5.24% |
| វិស័យសេដ្ឋកិច្ច | 869,771 | 1,154,557 | 32.74% | 10.35% | 1.41% |
| ចំណាយមិនទាន់បែងចែកមានមុខសញ្ញា | 916,838 | 1,340,954 | 46.26% | 12.02% | 1.64% |

សម្គាល់÷ (*) តួលេខប៉ាន់ស្មានអនុវត្តឆ្នាំ ២០១៥

# ជានិន្នាការ ចំណាយចរន្តវិស័យសង្គមកិច្ចកើនឡើងខ្លាំងជាងគេ

ចំណាយចរន្តថ្នាក់ជាតិតាមវិស័យ ជា % ផសស



# ការឧបត្ថម្ភពីថវិការដ្ឋដល់មន្ទីរពេទ្យគន្ធបុប្ផាកើនឡើងបន្តបន្ទាប់

ឯកតា លានរៀល



# ដំណើរឈានឆ្ពោះទៅរកការផ្លាស់ប្តូរប្រព័ន្ធថវិកា

## ក្រសួង ស្ថាប័ន ចំនួន ២៥ អនុវត្តថវិកាកម្មវិធីនៅឆ្នាំ ២០១៦



# ចំណាយវិនិយោគកាន់តែច្រើនឡើងដោយថវិកាជាតិ ឆ្លុះបញ្ចាំងពីការកើនឡើងនៃឯករាជ្យភាព

| ចំណាយ | ឯកតាលានរៀល | | | កំណើនប្រចាំឆ្នាំ | | | %ផសស | | |
|---|---|---|---|---|---|---|---|---|---|
| | ២០១៤ អនុ | ២០១៥ អនុ (*) | ២០១៦ ច្បាប់ | ២០១៤ អនុ | ២០១៥ អនុ (*) | ២០១៦ ច្បាប់ | ២០១៤ អនុ | ២០១៥ អនុ (*) | ២០១៦ ច្បាប់ |
| ចំណាយមូលធនថវិកាថ្នាក់ជាតិ | 5,863,490 | **5,375,120** | 6,305,488 | 0.91% | **-0.08%** | 9.47% | 8.66% | **7.17%** | 7.70% |
| វិនិយោគសាធារណៈ: ហិរញ្ញប្បទានក្នុងប្រទេស | 1,311,231 | 1,358,052 | 1,925,000 | 4.08% | 3.57% | 17.63% | 1.94% | 1.81% | 2.35% |
| វិនិយោគសាធារណៈ: ហិរញ្ញប្បទានក្រៅប្រទេស | 4,240,480 | 3,687,000 | 3,871,350 | -1.52% | -13.05% | 5.00% | 6.26% | 4.92% | 4.72% |
| ការទូទាត់ប្រាក់ខ្ចី | 311,779 | 330,068 | 509,138 | 28.70% | 5.87% | 16.62% | 0.46% | 0.44% | 0.62% |

សម្គាល់÷ (*) តួលេខប៉ាន់ស្មានអនុវត្តឆ្នាំ ២០១៥

# មូលហេតុនៃការបង្កើនពិដាននៃការខ្ចីពីបរទេស

១ ផ្អែកលើលទ្ធផលនៃការសិក្សា និងវាយតម្លៃជាបច្ចេកទេស ដូចបានគូសរំលេចនៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ រាជរដ្ឋាភិបាលបានកំណត់ទំហំនៃការខ្ចីថ្មីបន្ថែមសម្រាប់ឆ្នាំ២០១៦ ក្នុងរង្វង់ **៧០០ លានអេសដេអ៊ែរ,** ហើយនៅក្នុងសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ក៏បានកំណត់នូវទំហំនៃការខ្ចី ក្នុងកម្រិត **៧០០ លានអេសដេអ៊ែរ** តាមនោះដែរ។

២ ការបង្កើនពិដាននៃការខ្ចីថ្មីបន្ថែមនេះ គឺដើម្បីប៉ះប៉ូវការធ្លាក់ចុះនៃហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍន៍ផងដែរ។ ការធ្លាក់ចុះនៃហិរញ្ញប្បទានឥតសំណង គឺដោយសារម៉្យាង ប្រទេសកម្ពុជាយើងមានកម្រិតអភិវឌ្ឍន៍ខ្ពស់ជាងមុន ដែលធ្វើឱ្យដៃគូអភិវឌ្ឍងាកមកផ្តល់ឥណទានសម្បទានជាជំនួសវិញកាន់តែច្រើន និងម៉្យាងទៀត ប្រទេសដែលធ្លាប់តែផ្តល់ហិរញ្ញប្បទានឥតសំណង កំពុងតែជួបការលំបាកផ្ទាល់ខ្លួនរបស់គេផងដែរ។

៣ ការខិតខំថ្មីរបស់រាជរដ្ឋាភិបាលក្នុងឆ្នាំ២០១៦ មានគោលដៅសម្រាប់ហិរញ្ញប្បទានកម្មវិធី/គម្រោងក្នុងវិស័យអាទិភាព សំដៅទ្រទ្រង់ចីរភាពកំណើន និងបង្កើនផលិតភាពសេដ្ឋកិច្ច រួមមាន÷

- **វិស័យអគ្គិសនី÷** គម្រោងពង្រីកខ្សែបញ្ជូន និងបណ្តាញចែកចាយអគ្គិសនីទៅទីប្រជុំជន និងជនបទ ក្នុងគោលដៅពង្រីកវិសាលភាពនៃការផ្គត់ផ្គង់អគ្គិសនី និងបញ្ចុះតម្លៃអគ្គិសនីនៅជនបទ មកនៅត្រឹមរង្វង់ ៨០០ រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង ក្នុងឆ្នាំ២០១៦ (សម្រាប់តំបន់គ្របដណ្តប់ដោយបណ្តាញ EDC)។
- **វិស័យធារាសាស្ត្រ÷** គម្រោងប្រព័ន្ធធារាសាស្ត្រនិងការពារទឹកជំនន់ក្នុងខេត្តបន្ទាយមានជ័យ ដោយរួមទាំងគម្រោងប្រព័ន្ធធារាសាស្ត្រអូរខែជន, គម្រោងអភិវឌ្ឍន៍ធនធានទឹកស្ទឹងស្វាហាប់ ក្នុងខេត្តកំពង់ស្ពឺ, គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ នៅខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី។
- **វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត÷** គម្រោងកែលម្អផ្លូវជាតិលេខ ៣, លេខ ៥, លេខ ៤៨, និងគម្រោងគ្រប់គ្រងទ្រព្យសម្បត្តិផ្លូវថ្នល់។ល។
- **វិស័យអាទិភាពផ្សេងទៀត÷** គម្រោងកសិកម្ម, អប់រំ, សុខាភិបាល, ផ្គត់ផ្គង់ទឹកស្អាត, និងអភិបាលកិច្ច។

៤ មានការធ្វើប្រក្រតីកម្មកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍចាស់ឡើងវិញ (ធនាគារពិភពលោក) តាមរយៈការទទួលបានឥណទានដែលមានកម្រិតសម្បទានខ្ពស់ ដោយមានអត្រាការប្រាក់ **0,៧៥%** ក្នុងមួយឆ្នាំ និងរយៈពេលសង **៤0ឆ្នាំ** ក្នុងនោះ រយៈពេលអនុគ្រោះ **១0ឆ្នាំ** សម្រាប់ហិរញ្ញប្បទាន÷ គម្រោងទ្រទ្រង់វិស័យសុខាភិបាល, គម្រោងបែងចែកដីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច, គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ, គម្រោងគ្រប់គ្រងទ្រព្យសម្បត្តិផ្លូវថ្នល់។ល។

៥ ការបង្កើនពិដាននៃការខ្ចីថ្មីបន្ថែមដល់ **៧00 លានអេសដេអ៊ែរ**នេះ គ្រាន់តែជាការគ្រោងប៉ុណ្ណោះ។ ការអនុវត្តជាក់ស្តែង គឺអាចមិនដល់ពិដានឥណទានអនុញ្ញាតដោយច្បាប់នោះទេ។ ជាក់ស្តែង ក្នុងឆ្នាំ ២០១៣ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងចំនួនប្រមាណ **៥១៩ លានអេសដេអ៊ែរ** ធៀបនឹងច្បាប់អនុញ្ញាត **៦00 លានអេសដេអ៊ែរ**, ក្នុងឆ្នាំ២០១៤ ចំនួនប្រមាណ **៥១១ លានអេសដេអ៊ែរ** ធៀបនឹងច្បាប់អនុញ្ញាត **៦00 លានអេសដេអ៊ែរ**, និងក្នុងឆ្នាំ២០១៥នេះ អាចមានចំនួនប្រមាណ **៥៦0 លានអេសដេអ៊ែរ** ធៀបនឹងច្បាប់អនុញ្ញាត **៦00 លានអេសដេអ៊ែរ**។

# ១.២.២ ការវិភាគថវិកាថ្នាក់ជាតិ តាមក្រសួង ស្ថាប័ន

# ចំណាយថវិកាសរុបរបស់ក្រសួង ស្ថាប័ន តាមលំដាប់ ទំហំទឹកប្រាក់ (ចំណាយចរន្ត និង ចំណាយមូលធន)

<u>ឯកតា លានរៀល</u>

- ក្រសួងក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ មានថវិកា<u>ចំណាយសរុប 2,402,742 លានរៀល</u>
- ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម មានថវិកា<u>ចំណាយសរុប 1,106,825 លានរៀល</u>
- ក្រសួងសាធារណការនិងដឹកជញ្ជូន និង ក្រសួងអភិវឌ្ឍន៍ជនបទ មានថវិកា<u>ចំណាយសរុប 2,902,113 លានរៀល</u>



# ចំណាយចរន្តតាមលំដាប់ក្រសួង ពីធំ ទៅ តូច



# ចំណាយបន្ទុកបុគ្គលិក និងមិនមែនបន្ទុកបុគ្គលិកឆ្នាំ២០១៦ តាមលំដាប់ក្រសួង ពីធំ ទៅ តូច




-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានចំណាយក្រៅបន្ទុកបុគ្គលិកធំ (៨៦,១%) ដោយសារ ការកើនឡើងនូវថវិកាសម្រាប់បង្វិលសងអាករលើតម្លៃបន្ថែម (VAT Refund) និង ការកើនឡើងនូវបន្ទុករបស់រដ្ឋលើ អាករលើតម្លៃបន្ថែមរបបនាំចូលទំនិញជាសម្ភារៈកសិកម្ម និង ពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ

-ក្រសួងការពារជាតិ មានចំណាយបន្ទុកបុគ្គលិកធំ ( ៧៩,៩%)

- ក្រសួងមហាផ្ទៃ មានចំណាយបន្ទុកបុគ្គលិកធំ ( ៦៧,៩%) ហើយចំណាយមិនមែនបន្ទុកបុគ្គលិក ផ្តោតជាសំខាន់លើការបន្តធ្វើអត្តសញ្ញាណប័ណ្ណគំរូថ្មីជំហ៊ានទី៣ ជូនប្រជាជន

# ទំហំកំណើនចំណាយចរន្តថ្នាក់ជាតិតាមក្រសួងឆ្នាំ ២០១៦ ធៀបច្បាប់ឆ្នាំ ២០១៥ តាមលំដាប់ ពីធំ ទៅ តូច



# កំណើនចំណាយចរន្តជាភាគរយតាមក្រសួងឆ្នាំ ២០១៦
# ធៀបច្បាប់ឆ្នាំ ២០១៥ តាមលំដាប់ ពីធំ ទៅ តូច



# ១.៣ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

# គម្រោងថវិកាថ្នាក់ក្រោមជាតិ ឆ្នាំ២០១៦

| ថវិកាថ្នាក់ក្រោមជាតិ | ២០១៥អនុ (*) | ច្បាប់ ២០១៦ | កំណើនធៀបអនុ.១៥ | %នៃ ផសស |
|---|---|---|---|---|
| **ចំណូលចរន្តថវិកាថ្នាក់ក្រោមជាតិ** | **687,664** | **821,242** | **19.42%** | **1.00%** |
| ចំណូលសារពើពន្ធ | 651,813 | 777,504 | 19.28% | 0.95% |
| ចំណូលមិនមែនសារពើពន្ធ | 35,851 | 43,738 | 22% | 0.05% |
| **សរុបចំណាយថវិកាថ្នាក់ក្រោមជាតិ** | **1,107,196** | **1,334,525** | **20.53%** | **1.63%** |
| ចំណាយចរន្ត | 974,335 | 1,181,620 | 21.27% | 1.44% |
| ចំណាយមូលធន | 132,861 | 152,905 | 15.09% | 0.19% |
| **ឱនភាពថវិកា** | **-442,896** | **-513,283** | **-15.89%** | **-0.63%** |
| **ឧបត្ថម្ភដល់ថ្នាក់ក្រោមជាតិ** | **442,896** | **513,283** | **15.89%** | **0.63%** |
| រាជធានី ខេត្ត | 93,241 | 105,741 | **13.41%** | 0.13% |
| ក្រុង ស្រុក | 77,701 | 99,132 | 27.58% | 0.12% |
| មូលនិធិឃុំសង្កាត់ | 271,954 | 308,410 | 13.41% | 0.38% |

សម្គាល់÷ (*) តួលេខប៉ាន់ស្មានអនុវត្តឆ្នាំ ២០១៥

# ការឧបត្ថម្ភធនដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ កើនឡើងជាបន្តបន្ទាប់



# គោលនយោបាយបៀវត្សថ្នាក់ក្រោមជាតិ ឆ្នាំ ២០១៦

- **ក្រុមប្រឹក្សារាជធានី ខេត្ត÷** តម្លើងប្រាក់បំណាច់ប្រធាន ពី ១លានរៀល ដល់ **១,០៩ លានរៀល** និងសមាជិកពី៨០ម៉ឺនរៀល ដល់ **៨៧ម៉ឺនរៀល** ចាប់ពីខែមេសា ២០១៦
- **ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ÷** តម្លើងប្រាក់បំណាច់ប្រធាន ពី ៧០ម៉ឺនរៀល ដល់ **៨១ម៉ឺនរៀល** និងសមាជិក ឡើងពី៥០ម៉ឺនរៀល ដល់ **៦៥ម៉ឺនរៀល** ចាប់ពីខែមេសា ២០១៦
- **ក្រុមប្រឹក្សាឃុំ សង្កាត់÷**តម្លើងប្រាក់បំណាច់ប្រធានពី ៥៧ម៉ឺនរៀល ដល់ **៧៥ម៉ឺនរៀល**, ជំទប់ទី១ ទី២ ចៅសង្កាត់រងទី១ ទី២ ពី ៤០ម៉ឺនរៀល ដល់ **៥៥ម៉ឺនរៀល** និងសមាជិកពី ៣៥ម៉ឺនរៀល ដល់ **៤៨ម៉ឺនរៀល** ចាប់ពីខែមេសា ២០១៦
- **មេភូមិ÷ តម្លើង**ប្រាក់បំណាច់ប្រធាន ពី ១៦ម៉ឺនរៀល ដល់ **២០ម៉ឺនរៀល** ,ជំនួយការភូមិ ពី ១៤ម៉ឺនរៀល ដល់ **១៦ម៉ឺនរៀល**, និង សមាជិក ពី ១២ម៉ឺនរៀល ដល់ **១៤ម៉ឺនរៀល** ចាប់ពីខែមេសា ២០១៦

# ថវិការដ្ឋឆ្នាំ ២០១៦ មិនត្រឹមតែអាចធានាបាននូវស្ថិរភាព ថែមទាំងគ្រោងសម្រេចអតិរេកថវិកាចំនួន ១៥០ប៊ីលានរៀល

- **អតិរេកចរន្ត÷**
  - **គម្រោងឆ្នាំ ២០១៦:** គ្រោងអតិរេកចរន្ត ឱ្យបានក្នុងកម្រិតប្រមាណ <u>**២,៩៣%**</u> នៃ ផសស ធៀបច្បាប់ឆ្នាំ ២០១៥ ដែលបានគ្រោងត្រឹម <u>**២,៥០%**</u> នៃ ផសស
- **ឱនភាពថវិកាសរុប÷**
  - ឱនភាពថវិកាសរុបឆ្នាំ ២០១៦ ស្មើនឹង <u>**-៤,៧៩%**</u> នៃ ផសស ដែលធ្លាក់ចុះពី <u>**-៥,១៩%**</u> នៃ ផសស នៃច្បាប់ឆ្នាំ ២០១៥
  - ត្រូវបានបំពេញបន្ថែមដោយហិរញ្ញប្បទានក្រៅប្រទេស : <u>**៤,៧២%**</u> នៃ ផសស និងមូលនិធិទ្រទ្រង់ថវិកា: <u>**០,២៥%**</u> នៃ ផសស
- **អតិរេកថវិកា ដើម្បីបង្កើនប្រាក់បញ្ញើរាជរដ្ឋាភិបាល÷**
  - **ចំនួន <u>១៥០ ប៊ីលានរៀល</u> ស្មើនឹង <u>០,១៨%</u>នៃ ផសស**

# ២.បញ្ហាប្រឈម និង វិធានការ ក្នុងការអនុវត្តថវិកាឆ្នាំ ២០១៦

# ២.១ បញ្ហាប្រឈមក្នុងការអនុវត្តថវិកាឆ្នាំ ២០១៦

## ២.១.១ ផ្នែកចំណូល

- ចំណូលនៅមិនទាន់អាចឆ្លើយតបនឹងទំហំនៃសេចក្តីត្រូវការផ្នែកចំណាយនៅឡើយ
- ចំណូលសារពើពន្ធ ស្ថិតក្នុងសេណារីយ៉ូសុទិដ្ឋិនិយមកម្រិតខ្ពស់ គួបផ្សំនឹងការធ្លាក់ចុះកាន់តែច្រើននូវចំណូលពន្ធគយ ដោយសារការអនុវត្ត កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី
- មិនបង្កើតប្រភេទពន្ធថ្មី មិនដំឡើងអត្រាពន្ធ និងអាករ លើកលែងតែ អាករពិសេសលើទំនិញប្រណិត ទំនិញប៉ះពាល់សុខភាព និង/ ឬបរិស្ថាន និងការប៉ះប៉ូវការបាត់បង់ចំណូល
- ការទប់ស្កាត់អំពើរត់ពន្ធ និងការគេចវេះពន្ធគ្រប់រូបភាព នៅជួបប្រទះការលំបាកច្រើន
- វប្បធម៌បង់ពន្ធនៅតែជាបញ្ហាចោទនៅឡើយ
- ចំណូលមិនមែនសារពើពន្ធទាមទារឱ្យមានការកិច្ចប្រឹងប្រែង និងកិច្ចសហការបន្ថែមពីស្ថាប័នដែលពាក់ព័ន្ធ

## ២.១.២ ផ្នែកចំណាយ

- សម្ពាធនៃចំណាយ ទាំងចំណាយបៀវត្ស ទាំងចំណាយមិនមែនបៀវត្ស បានកើនឡើងឥតឈប់ឈរ
- ការផ្តល់អាទិភាពចាំបាច់បំផុតដល់ការតម្លើងបៀវត្សជូនមន្ត្រីរាជការ ក្នុងគោលដៅឆ្ពោះទៅរកបៀវត្សអប្បបរមា **ជាង ១លានរៀល នៅឆ្នាំ ២០១៨**
- ការបង្កើនចំណាយមួយចំនួនដែលមានភាពចាំបាច់ខ្លាំង ដើម្បីសម្រេចបាននូវអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេស ការអនុវត្តសកម្មភាពកែទម្រង់គ្រប់វិស័យ និងការវិនិយោគទ្រទ្រង់កំណើនសេដ្ឋកិច្ច
- សមត្ថភាពស្ថាប័ន និងមន្ត្រីនៅមានកម្រិត  ក្នុងការរៀបចំ និងអនុវត្តថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# ២.២ ទិសដៅការងារក្នុងការអនុវត្តថវិកាឆ្នាំ ២០១៦

## ២.២.១ ទិសដៅការពង្រឹង និង កែលម្អគោលនយោបាយ និងការគ្រប់គ្រងចំណូល

- ពុំមានគោលការណ៍បង្កើតបន្ទុកពន្ធថ្មី ឬ តម្លើងពន្ធបន្ថែមដល់ប្រជាជន និងធុរជន លើកលែងតែអាករពិសេសលើទំនិញប្រណិត ទំនិញប៉ះពាល់សុខភាព និង/ឬបរិស្ថាន និង ការប៉ះប៉ូវការបាត់បង់ចំណូលពីអនុលោមភាពតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី
- ពង្រឹងការអនុវត្ត គោលនយោបាយ និងច្បាប់ដែលមានស្រាប់ ជាពិសេស ការលើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើរត់ពន្ធនិងការគេចវេះពន្ធគ្រប់រូបភាពឱ្យដល់ឫសគល់
- កែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូល ទាំងក្នុងផ្នែកគយ និងផ្នែកពន្ធដារ និងផ្នែកមិនមែនសារពើពន្ធ ជាពិសេសតាមរយៈការបន្តអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**

## ២.២.២ វិធានការពង្រឹង និង កែលម្អគោលនយោបាយ និងការគ្រប់គ្រងចំណាយ

- បន្តបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា នៅដំណាក់កាលរៀបចំ
- បន្តបង្កើនប្រសិទ្ធភាពចំណាយ នៅដំណាក់កាលអនុវត្ត តាមរយៈការជំរុញការអនុវត្តឱ្យចំទិសដៅ ទៅតាមអាទិភាពគោលនយោបាយ តាមស្មារតីនៃការរៀបចំ ការលើកកម្ពស់តម្លៃលុយ និងការលើកកម្ពស់ប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយ
- បន្តជំរុញការធ្វើវិសហមជ្ឈការការត្រួតពិនិត្យហិរញ្ញវត្ថុ តាមរយៈការផ្ទេរសិទ្ធិអំណាចក្នុងការចាត់ចែងចំណាយ ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅក្រសួង ស្ថាប័ន និងពីអង្គភាពហិរញ្ញវត្ថុ នៃក្រសួង ស្ថាប័ន ទៅអង្គភាពអនុវត្តការងារផ្ទាល់នៅតាមក្រសួង ស្ថាប័ន
- បន្តកាត់បន្ថយនីតិវិធីចំណាយ ជាពិសេស បរិបថចំណាយថ្មីសម្រាប់ការអនុវត្តថវិកាកម្មវិធី តាមរយៈការបង្កើនការផ្ទេរពីការត្រួតពិនិត្យមុនចំណាយ ទៅត្រួតពិនិត្យក្រោយចំណាយ និងការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មានវិទ្យា

## ២.២.២ វិធានការពង្រឹង និង កែលម្អគោលនយោបាយ និងការគ្រប់គ្រងចំណាយ (ត)

- ពង្រឹងការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវរាល់វិធានការនិងបទប្បញ្ញត្តិ ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធលទ្ធកម្មសាធារណៈជាធរមាន ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព និងតម្លាភាពក្នុងចំណាយសាធារណៈ
- បន្តកែលម្អ និងបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធកត់ត្រា និងរបាយការណ៍ហិរញ្ញវត្ថុ និងការអនុវត្តថវិកាជាមួយនឹងការកែលម្អការអនុវត្តប្លង់គណនេយ្យថ្មី
- ដាក់អនុវត្តប្រព័ន្ធមាតិកាថវិកាថ្មីជាបណ្តើរៗនូវចំណាត់ថ្នាក់ទាំង៧រួមមានចំណាត់ថ្នាក់ សេដ្ឋកិច្ច ភូមិសាស្រ្ត រដ្ឋបាល កម្មវិធី មុខងារ គម្រោង និងប្រភពហិរញ្ញប្បទាន តាមរយៈប្រព័ន្ធគ្រប់គ្រងតាមព័ត៌មានវិទ្យា (FMIS)
- បន្តពង្រឹងនិងពង្រីកការអនុវត្តការទូទាត់ថវិកានិងការបើកប្រាក់បៀវត្ស តាមរយៈការប្រើប្រាស់ប្រព័ន្ធធនាគារ

# ២.២.៣ វិធានការអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ

ជំរុញអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ ជាពិសេស ÷

- កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ "ដំណាក់កាលទី ៣ ឆ្នាំ ២០១៦-២០១៨"
  - ការពង្រឹង និងពង្រីកការដាក់អនុវត្តថវិកាកម្មវិធីពេញលេញ និង អង្គភាពថវិកា ដើម្បីបង្កើនការផ្សារភ្ជាប់ថវិកា ទៅនឹងគោលនយោបាយ និងការបង្កើនគណនេយ្យភាពចំពោះសមិទ្ធកម្ម
- ការអនុវត្តការកែទម្រង់រដ្ឋបាលសាធារណៈ
  - កែលម្អការគ្រប់គ្រងធនធានមនុស្ស ដើម្បីបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ ព្រមជាមួយនឹងគោលនយោបាយដំឡើងបៀវត្ស
  - បង្កើតយន្តការ និងបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យក្របខណ្ឌមន្ត្រីរាជការ
  - ពង្រឹងការផ្តល់ទិដ្ឋាការឱ្យរើសមន្ត្រីរាជការថ្មីបន្ថែម តាមលទ្ធភាពថវិកាជាតិ
  - បន្តលុបបំបាត់មន្ត្រីខ្មោច " ទាំងខ្មោចងាប់ និង ខ្មោចរស់"
- ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ការកែទម្រង់ចាំបាច់ផ្សេងៗទៀត ដើម្បីលើកកម្ពស់សេវាសាធារណៈ និង យុត្តិធម៌សង្គម

# ២.២.៤ វិធានការពន្ធដារ

**១.** *ធ្វើវិសោធនកម្មមាត្រា៤ នៃច្បាប់ស្តីពីសារពើពន្ធ* ដើម្បីលុបចោលរបបពន្ធម៉ៅការ ដោយបង្កើត របបកំណត់ពន្ធតែមួយ គឺ របបស្វ័យប្រកាសដោយបែងចែកអ្នកជាប់ពន្ធជាបីប្រភេទ÷

១. អ្នកជាប់ពន្ធតូច

២. អ្នកជាប់ពន្ធមធ្យម

៣. អ្នកជាប់ពន្ធធំ

ការលុបចោលរបបពន្ធម៉ៅការនេះ គឺដើម្បីបញ្ចប់នូវបញ្ហាស្មុគស្មាញមិនចេះចប់ជាមួយអ្នកជាប់ពន្ធតូចតាច ដែលប្រកបរបបអាជីវកម្មគ្រាន់តែដើម្បីចិញ្ចឹមជីវិតផង និងលុបបំបាត់កន្លែងលាក់ខ្លួនរបស់អ្នកជាប់ពន្ធដែលត្រូវបញ្ចូលក្នុងរបបស្វ័យប្រកាសផង។ ទន្ទឹមនេះ ចំណូលពន្ធបានមកពីរបបម៉ៅការគឺតិចជាង ១% នៃចំណូលពន្ធសរុប តែប្រើប្រាស់មន្ត្រីពន្ធដាររហូតដល់ប្រមាណ ៦០%។

# ២.២.៤ វិធានការពន្ធដារ (ត)

**២.** *វិសោធនកម្មមាត្រា ៦ នៃច្បាប់ស្តីពីសារពើពន្ធ* ដើម្បីកំណត់នូវវិធានគណនេយ្យសម្រាប់អ្នកជាប់ពន្ធទាំងបីប្រភេទ ដោយក្នុងនោះ អ្នកជាប់ពន្ធតូចត្រូវប្រើវិធានគណនេយ្យសាមញ្ញ ហើយអ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ ត្រូវប្រើវិធានគណនេយ្យតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា។

ការកំណត់វិធានគណនេយ្យខាងលើ គឺដើម្បីគាំទ្រដល់ការលុបចោលរបបម៉ៅការ និងជួយបង្កលក្ខណៈងាយស្រួលដល់ម្ចាស់សហគ្រាសតូចៗក្នុងការកាន់កាប់បញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ។

# ២.២.៤ វិធានការពន្ធដារ (ត)

៣. *ធ្វើវិសោធនកម្មមាត្រា ៣៩ នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ១៩៩៥* ដើម្បីកំណត់ឡើងវិញនូវទំហំទឹកប្រាក់ពន្ធប៉ាតង់ត្រូវបង់ឱ្យស្របទៅតាមការវិវឌ្ឍន៍នៃសេដ្ឋកិច្ចបច្ចុប្បន្ន និងដើម្បីធ្វើឱ្យការកំណត់ពន្ធនេះកាន់តែមានលក្ខណៈសាមញ្ញ ងាយយល់ ងាយអនុវត្ត និងមានសមធម៌ ពិសេសចំពោះ សហគ្រាសតូចៗ។

# ២.២.៤ វិធានការពន្ធដារ (ត)

**៤.** *ធ្វើវិសោធនកម្មមាត្រា១៤ នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ១៩៩៨, មាត្រា១១ នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៤*

- <u>លុបចោលប្រាក់ពន្ធ</u>លើមធ្យោបាយដឹកជញ្ជូន និងយានជំនិះមួយចំនួនដូចខាងក្រោម÷
  1. ទោចក្រយានយន្ត និងត្រីចក្រយានយន្ត ដើម្បីកាត់បន្ថយបន្ទុកចំណាយរបស់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប
  2. ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែល ដើម្បីបន្តលើកស្ទួយដល់វិស័យ កសិកម្មពិសេសដើម្បីលើកទឹកចិត្ត និងសម្រាលបន្ទុករបស់កសិករ
  3. ជលយានយន្តធុនតូច ដើម្បីកាត់បន្ថយបន្ទុកចំណាយរបស់ប្រជាពលរដ្ឋដែលប្រើប្រាស់ជលយានយន្តទាំងនោះជាមធ្យោបាយដឹកជញ្ជូន និងប្រកបអាជីវកម្មជាលក្ខណៈគ្រួសារ។

# ២.២.៤ វិធានការពន្ធដារ (ត)

- កែសម្រួលនិងកំណត់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះ ចំពោះរថយន្ត ដឹកទំនិញ និង រ៉ឺម៉កសណ្តោង ដែលជាប្រភេទរថយន្តធុនធ្ងន់ ដែលធ្វើឱ្យមានការប៉ះពាល់ខ្លាំងដល់ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងបរិស្ថាន និងដើម្បីប៉ះប៉ូវចំណូលដែលបាត់បង់ ពីការលុបចោលពន្ធខាងលើ។

ទន្ទឹមនឹងការលុបចោលប្រាក់ពន្ធមួយចំនួនលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះ ដូចបានលើកឡើងខាងលើ ដែលមានចំណូលពន្ធសរុបចំនួន ៥ ៨០១ លានរៀល ការកែសម្រួលប្រាក់ពន្ធចំពោះរថយន្តដឹកទំនិញធុនធ្ងន់ និងរ៉ឺម៉កសណ្តោង ក្រោយពីបានទូទាត់ប្រាក់ពន្ធដែលលុបចោល អាចធ្វើឱ្យមានកំណើនចំណូលប្រមាណ ២៣ ប៊ីលានរៀល។

# ៣. សេចក្តីសន្និដ្ឋាន

ថវិកាឆ្នាំ២០១៦ ឆ្លុះបញ្ចាំងពីការបង្កើនជាសារវន្តអំពីប្រសិទ្ធភាពនៃការរៀបចំ និងការវិភាជថវិកា ក្នុងការឆ្លើយតបទៅនឹងគោល-នយោបាយសំខាន់ៗ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។ ប៉ុន្តែ លទ្ធផលចុងក្រោយ គឺអាស្រ័យយ៉ាងខ្លាំងទៅលើសុឆន្ទៈ និងការទទួលខុសត្រូវ ព្រមទាំងសមត្ថភាពគ្រប់គ្រង និងចាត់ចែងថវិការបស់ក្រសួងសាមីផ្ទាល់ នៅក្នុងដំណាក់កាលអនុវត្ត។